សាលាឧទ្ធរណ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តាងនាមប្រជារាស្ត្រខ្មែរ**

សំណុំរឿងព្រហ្មទណ្ឌ

សាលាឧទ្ធរណ៍ភ្នំពេញ

លេខ ១១០៩/២១-១១-១២ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-៩៣

**សាលដីកា**

បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៩-១២-១៣

លេខ ៧៧ក្រ៣"ឃ"ចុះ ដែលមានសមាសភាពដូចតទៅ៖

ថ្ងៃទី ២៤-១២-២០១៣

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដែលមានលេខ ១១០៩ ចុះថ្ងៃទី ២១-១១-២០១២ រវាង ៖

-ជនជាប់ចោទឈ្មោះ

១-[redacted] **វណ្ណា** ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរ នគរបាលបង្ក្រាបគ្រឿងញៀន កើតនៅភូមិមាន់ជប់ ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម មានទីលំនៅផ្ទះលេខ[redacted]រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]"ស" ម្តាយឈ្មោះ [redacted]"ស" ប្រពន្ធឈ្មោះ [redacted]"រ" មានកូន០៣នាក់ ទោសពីមុនគ្មាន (ឃុំខ្លួន)។ (ដើមបណ្តឹងឧទ្ធរណ៍)

២-[redacted] **គួច** ភេទប្រុស ជាតិខ្មែរ..................។

៣-[redacted] **តំណា** ភេទប្រុស ជាតិខ្មែរ....................។

៤-[redacted] ភេទប្រុស ជាតិខ្មែរ.......................។

**ត្រូវជាប់ចោទពីបទ** ៖ លក់ដូរជួញដូរគ្រឿងញៀនខុសច្បាប់

ប្រព្រឹត្តនៅភូមិនិមិត្ត២ ឃុំសង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ០៨-៥-២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស



Scanned with CamScanner

តាមមាត្រា ៣៣ថ្មី ចំណុចទី២-ជ នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៦រឿងហេតុមានដូចតទៅ**

កាលពីថ្ងៃទី ០៦-៥-២០១០ ឈ្មោះ អូ ភេទប្រុស (គ្មានសាវតាជាតិ) និងឈ្មោះ ឧត្តម ភេទប្រុស (គ្មានសាវតាជាតិ) រស់នៅភ្នំពេញបានទាក់ទងតាមទូរស័ព្ទមកឈ្មោះ [redacted] ភ័ណ ភេទប្រុស និងប្រពន្ធឱ្យជួយរកទិញថ្នាំញៀន នៅប៉ោយប៉ែត បន្ទាប់មកឈ្មោះ [redacted] ភ័ណ បានទូរស័ព្ទសួរឈ្មោះ [redacted] គួន បានទាក់ទៅឈ្មោះ [redacted] ធារ៉ា ដើម្បីរកទិញថ្នាំញៀន។ លុះដល់ថ្ងៃទី ០៨-៥-២០១១ ឈ្មោះ [redacted] គួន ទូរស័ព្ទទៅប្រាប់ឈ្មោះ [redacted] ភ័ណ ថាថ្នាំមកដល់ហើយ លុះដល់ពេលល្ងាច ឈ្មោះ [redacted] ភ័ណ ជិះម៉ូតូឌុបឈ្មោះ អូ ចំណែកឈ្មោះ [redacted] គួន ជិះម៉ូតូឌុបឈ្មោះ [redacted] ធារ៉ា និងឈ្មោះ ធី ទៅកន្លែងណាត់ជួបគ្នាដើម្បីដោះដូរថ្នាំញៀន នៅសាលារៀននិមិត្ត ពេលទៅដល់មានឡានចំនួនពីរគ្រឿងនៅចាំជាស្រេច ហើយឈ្មោះ [redacted] ធារ៉ា ដើម្បីយកថ្នាំញៀនមួយកញ្ចប់ពីឡាន និងហុចថ្នាំញៀននោះឱ្យទៅឈ្មោះ [redacted] គួន ដើម្បីប្រគល់ឱ្យអ្នកនៅលើឡានមួយទៀត ហើយត្រូវសមត្ថកិច្ចចេញមកព័ទ្ធចាប់បានឈ្មោះ [redacted] គួន និងឈ្មោះ [redacted] ភ័ណ ព្រមទាំងដកហូតថ្នាំញៀនចំនួន ១៩៩២គ្រាប់ ចំណែកអ្នកផ្សេងទៀតជិះម៉ូតូគេចខ្លួនបាត់ ហើយឈ្មោះ [redacted] គួន បានបញ្ជាក់ថា ថ្នាំញៀននេះទិញពីឈ្មោះ [redacted] វណ្ណា។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៩៥"ង" ចុះថ្ងៃទី ០៨-០៨-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារសម្រេចដូចតទៅៈ

១-រកឃើញជនជាប់ចោទឈ្មោះ [redacted] វណ្ណា ភេទប្រុស កើតឆ្នាំ ១៩៧៥ ,ឈ្មោះ [redacted] គួន ភេទប្រុស កើតឆ្នាំ ១៩៦៩ ,ឈ្មោះ [redacted] ធារ៉ា ភេទប្រុស កើតឆ្នាំ ១៩៨៤ និងឈ្មោះ [redacted] ភ័ណ ភេទប្រុស កើតឆ្នាំ ១៩៧៨ មានពិរុទ្ធភាពពីបទៈ ជួញដូរគ្រឿងញៀនខុសច្បាប់ តាមមាត្រា ៣៣ថ្មី ចំណុចទី២-ជ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅភូមិនិមិត្ត២ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ០៨-៥-២០១០។

២-ផ្តន្ទាទោសជនជាប់ចោទៈ

-ឈ្មោះ [redacted] វណ្ណា ដាក់ពន្ធនាគារកំណត់ចំនួន ០៧"ប្រាំពីរ" ឆ្នាំ។

-ឈ្មោះ [redacted] ធារ៉ា ដាក់ពន្ធនាគារកំណត់ចំនួន ០៦"ប្រាំមួយ" ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ។

-ឈ្មោះ [redacted] ភ័ណ្ឌ និងឈ្មោះ [redacted] គួន ដាក់ពន្ធនាគារកំណត់ចំនួន០៥"ប្រាំ"ឆ្នាំ ដោយអនុវត្តទោសក្នុងពន្ធនាគារចំនួន៣"បី"ឆ្នាំ ហើយមូលទោសលើសពីនេះត្រូវបានព្យួរទោសធម្មតា។

៣-បង្គាប់ឱ្យចេញដីកាចាប់ខ្លួនឈ្មោះ [redacted] ធារ៉ា ភេទប្រុស កើតឆ្នាំ ១៩៨៤ យកមកអនុវត្តទោសអំណាចសាលក្រមនេះ។

៤-វត្ថុតាងរួមមានៈ

-ថ្នាំញៀនចំនួន ១៩៧២"មួយពាន់ប្រាំបួនរយចិតសិបពីរ" គ្រាប់សម្រេចរឹបអូស និងបំផ្លាញចោល។

-រថយន្តម៉ាក TOYOTA Land Cruiser ពណ៌ទឹកប៊ិច ចង្កូតឆ្វេង ស៊េរីឆ្នាំ ១៩៩៨ ពាក់ស្លាក

បន២.៣៩៩៩ ចំនួន ០១"មួយ"គ្រឿង កូនស្លាកកុងតាក់រថយន្តចំនួន០១"មួយ" ទូរស័ព្ទដៃម៉ាក NOKIA Model 1202-2 TypeRH 112 និងស៊ីមលេខ ០៩៧ ៦៧៧ ៧៨១ ចំនួន០១"មួយ" គ្រឿង , គ្រាប់អាវុធឡុកចំនួន១៩គ្រាប់ "ដប់ប្រាំបួន" ,បង់គ្រាប់ចំនួន២"ពីរ" ប័ណ្ណនគរបាល២ "ពីរ" សន្លឹក ប័ណ្ណ អហ១"មួយ" សន្លឹកសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជម្រះនិងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំងបីនាក់ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ជាវ៉ា ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**-បានឃើញ**ឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤-៩-២០១២ របស់ឈ្មោះ [redacted] **វណ្ណា** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៥"ង" ចុះថ្ងៃទី ០៨-៨-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ លើចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ**របាយការណ៍របស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ០៥-០៤-២០១៣។

**-បានឃើញ**សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ២៧-៦-២០១៣។

## នាពេលសវនាការសាលាឧទ្ធរណ៍

ចៅក្រមអានរបាយការណ៍រឿង

-ឈ្មោះ [redacted] វណ្ណា បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍ដោយសារមិនបានប្រព្រឹត្តក្នុងរឿងហ្នឹង ផងមកដាក់ទោស០៧ឆ្នាំ ហើយរឹបអូសយកឡានទៀត និងសូម្បីតែស្លាកលេខ ន.ប គឺយកពីក្នុងផ្ទះមិនមែនដាក់នៅក្នុងឡានទេ ព្រមទាំងបង់កាំភ្លើងនៅក្នុងទូរដែក ហើយក៏មិនមានគ្រឿងញៀនដូចការចោទប្រកាន់ និងគ្មានទំនាក់ទំនងជាមួយឈ្មោះ [redacted] គួន ដែរ។ សមត្ថកិច្ចចាប់ខ្លួននៅសៀមរាបតែម្តង ហើយបំបែកសំណុំរឿងជាពីរ ដោយបានដកហូតរថយន្តមួយគ្រឿង និងទូរស័ព្ទមួយគ្រឿង ពុំមានគ្រឿងញៀនទេ ហើយចំពោះគ្រាប់កាំភ្លើងខ្លួនដាក់នៅក្នុងទូរដែកអត់មានប្រើទេ រីឯអាវុធអត់មានដែរ ខ្លួនមិនធ្លាប់រកស៊ីគ្រឿងញៀនទេ ហើយចំពោះឈ្មោះ [redacted] ភ័ណ្ឌ [redacted] ជាវ៉ា ខ្លួនអត់ស្គាល់ទាំងអស់ រីឯឈ្មោះ [redacted] គួន ស្គាល់តាំងឆ្នាំ២០០០ ដោយរកស៊ីយួគីជាមួយគ្នា ហើយក៏បែកគ្នាដល់ឆ្នាំ២០០៦ បានជួបឈ្មោះនេះម្តងទៀតក៏បានបែកគ្នារហូតដល់ថ្ងៃចាប់ខ្លួន។ ខ្លួនមិនដែលមានទំនាស់ជាមួយឈ្មោះ [redacted] គួន នោះទេ ខ្លួនមិនមានភស្តុតាងបញ្ជាក់ថា ខ្លួនមិនបានប្រព្រឹត្តទេ គ្រាន់តែខ្លួនគ្មានថ្នាំញៀនដូចការចោទទេ និងនៅសាលាដំបូងឈ្មោះ [redacted] គួន មិនបានឆ្លើយថាយកថ្នាំញៀនពីខ្លួនដែរ។ ចំពោះការចោទប្រកាន់របស់តំណាងអយ្យការថ្នាក់ក្រោម ខ្លួនមិនទទួលទេ ដោយមិនបានប្រព្រឹត្ត រីឯឡានរបស់ខ្លួនអត់មានស្លាកលេខទេ។ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាលើកលែងចោទប្រកាន់ និងប្រគល់ទ្រព្យសម្បត្តិមកឱ្យខ្លួនវិញ។

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា

១-ជនដែលជាប់ពាក់ព័ន្ធនឹងជួញដូរគ្រឿងញៀនបែរជាត្រូវផ្តន្ទាទោសស្រាល ហើយបានស្ពានសំរាលទោសព្យួរទៅទៀត រីឯជនដែលត្រូវគេឆ្លើយដាក់បន្ទុកគ្មានភស្តុតាង រឹបអូសបានអ្វីសោះដែលត្រូវផ្តន្ទាទោសធ្ងន់ទៅវិញ។ អង្គហេតុនិងសេចក្តីសម្រេចនេះចម្លែកបំផុតនៅក្នុងសំណុំរឿងទាំងពីរនេះ ដែលមេក្លោងជួញដូរគ្រឿងញៀនត្រូវបានផ្តន្ទាទោសស្រាល និងបានស្ពានសំរាលទៀត



Scanned with CamScanner

រីឯអ្នកត្រូវគេឆ្លើយដាក់ត្រូវផ្តន្ទាទោសធ្ងន់ធ្ងរ និងជាប់ចោទពីបទជួញ ដូរគ្រឿងញៀនទៅវិញ។ តំណាងមហាអយ្យការសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាសេចក្តីសម្រេចនេះឡើងវិញ។

២-ប្រសិនជាយើងទុកឱ្យអង្គហេតុ និងសេចក្តីសម្រេចនេះនៅតម្កល់ទុកជាបានការនោះវាអាចជាយុត្តិសាស្ត្រធ្វើឱ្យយើងរងគ្រោះទាំងអស់គ្នាទៅថ្ងៃមុខ។ នេះប្រសិនបើសមត្ថកិច្ចចង់ធ្វើភ្នាក់ងារ ហើយចង់ដាក់បន្ទុកទៅលើអ្នកណាម្នាក់ រូបគេនឹងរងគ្រោះដូចក្នុងរឿងហ្នឹងដែរ។ សមត្ថកិច្ចចាប់បានគ្រឿងញៀនពីជនល្មើសបន្ទាប់មកឆ្លើយដាក់ថា បានទិញពីម្នាក់ទៀតដោយចាប់គេយកមកផ្តន្ទាទោសធ្ងន់ ដែលលើសពីនេះសុទ្ធតែជារឿងចម្លែក ដែលយកមនុស្សស្លូតត្រង់ឱ្យមកទទួលទោសជំនួសនូវអ្វីដែលខ្លួនឯងចង់បាន។ អំពើនេះជាគ្រោះថ្នាក់ដល់កូនចៅ,បងប្អូនយើង ប្រសិនបើសមត្ថកិច្ចចង់បង្កើតករណីដូចរឿងនេះ ដោយយកជនជួញដូរគ្រឿងញៀនដែលចាប់បានឱ្យឆ្លើយដាក់អ្នកទី៣ ដោយចោទប្រកាន់គេយ៉ាងធ្ងន់ធ្ងរ និងរឹបអូសយកទ្រព្យសម្បត្តិ ស្លាករថយន្ត និងសម្ភារៈដែលមិនបានឆែកឆេរឃើញក្នុងរថយន្តរបស់គេមកដាក់បន្ទុក។ អំពើដ៏ថោកទាបបំផុតនេះបានចោទប្រកាន់ទៅលើជនដែលស្លូតត្រង់ អង្គហេតុជាអំពើថោកទាប ។ តំណាងមហាអយ្យការយល់ឃើញថា មិនមានពិរុទ្ធភាពលើជនជាប់ចោទទេ សុំឱ្យដោះលែងឱ្យមានសេរីភាពឡើងវិញ។

-មេធាវី [redacted] ចន្ថា ការពារសិទ្ធិឱ្យឈ្មោះ [redacted] វណ្ណា បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលក្នុងសវនាការ និងការសន្និដ្ឋានរបស់តំណាងមហាអយ្យការ ខ្លួនសុំឯកភាពតាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ។ នៅចំពោះមុខអង្គសវនាការនេះកូនក្តីខ្លួនបានបញ្ជាក់យ៉ាងច្បាស់លាស់ថា ការចាប់ខ្លួនកូនក្តីខ្លួននៅខេត្តសៀមរាបពុំមានភស្តុតាងថ្នាំញៀនណាមួយនៅលើរថយន្តទេ ហើយអ្នកដែលចោទថា កូនក្តីខ្លួនជាអ្នកផ្តល់ថ្នាំញៀននោះបែរជាផ្តន្ទាទោសទាបជាងកូនក្តីខ្លួន រីឯកូនក្តីខ្លួនបានឆ្លើយគ្រប់ដំណាក់កាលនៃនីតិវិធីហើយថា កូនក្តីខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ចំពោះចម្លើយរបស់ឈ្មោះ [redacted] ភ័ណ, [redacted] គួន កូនក្តីខ្លួនបានបញ្ជាក់ថាអ្នកទាំងពីរមិនបានឆ្លើយដាក់បន្ទុកកូនក្តីខ្លួនទេចំពោះមុខអង្គសវនាការ ហើយក្នុងសាលក្រមថ្នាក់ក្រោមក៏មិនបានបញ្ជាក់ពីចម្លើយរបស់អ្នកទាំងពីរឆ្លើយដាក់ថាកូនក្តីខ្លួនជួញដូរគ្រឿងញៀនដែរ បើពិនិត្យលើភស្តុតាងដាក់បន្ទុកគឺពុំមានភស្តុតាងណាមួយ ឬសាក្សីណាមួយបញ្ជាក់ថា កូនក្តីខ្លួនជួញដូរគ្រឿងញៀននោះទេ។ ចំពោះការដកហូតរថយន្ត និងសំភារៈពាក់ព័ន្ធមួយចំនួននោះ ឃើញថារថយន្តមិនមែនប្រើប្រាស់ក្នុងមធ្យោបាយប្រព្រឹត្តការជួញដូរគ្រឿងញៀននោះទេ និងឯកសារ ឬឧបករណ៍មួយចំនួនទៀត ដែលកូនក្តីខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែមានសំរាប់ការពារខ្លួន។ តាមការពិនិត្យនិងពិចារណាពុំមានសត្ថុតាងណា ឬសាក្សីណាមួយដាក់បន្ទុកទៅលើកូនក្តីខ្លួនទេ ខ្លួនសំណូមពរយ៉ាងទទូចសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាឱ្យកូនក្តីខ្លួនរួចផុតពីបទចោទដោយសេចក្តីអនុគ្រោះ និងសុំឱ្យប្រគល់ទ្រព្យសម្បត្តិដែលបានដកហូតពីកូនក្តីខ្លួនមកប្រគល់ឱ្យកូនក្តីខ្លួនវិញ។

## សភាព្រហ្មទណ្ឌយល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤-០៩-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ប្តឹងឧទ្ធរណ៍

នឹងសាលក្រមព្រហ្មទណ្ឌលេខ ៩៥"ង"ចុះថ្ងៃទី ០៨-៨-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌអាចធ្វើការជំនុំជម្រះបាន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានឆ្លើយបដិសេធថា ខ្លួនពុំបានចូលរួមប្រព្រឹត្តបទល្មើសជាមួយឈ្មោះ [redacted] ធារ៉ា,ឈ្មោះ [redacted] ភ័ណ,ឈ្មោះ [redacted] គួន ឡើយ។ ប៉ុន្តែតាមចម្លើយរបស់ឈ្មោះ [redacted] ភ័ណ និងឈ្មោះ [redacted] គួន បានឆ្លើយសារភាពថាថ្នាំញៀននេះបានមកពីឈ្មោះ [redacted] ធារ៉ា តាមរយៈឈ្មោះ [redacted] វណ្ណា។

៣-រឿងក្តីនេះសាលាដំបូងបានលើកយកសំអាងហេតុមកបញ្ជាក់មានលក្ខណៈគ្រប់គ្រាន់ហើយ ហេតុនេះសភាព្រហ្មទណ្ឌឯកភាពតាមសំអាងហេតុនេះទាំងស្រុង ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ។

៤-តាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា តាមអង្គហេតុនេះ ឃើញពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីចោទប្រកាន់លើឈ្មោះ [redacted] វណ្ណា ឡើយ សុំឱ្យសភាព្រហ្មទណ្ឌ ពិចារណាអំពីការសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់។

៥-ផ្អែកតាមអង្គហេតុ និងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ភ័ណ និងឈ្មោះ យុន គួន អាចកំណត់បានថា ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ពិតជាបានចូលរួមប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

៦-មានសត្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] វណ្ណា ពីបទៈ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិនិមិត្ត២ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ០៨-៥-២០១០។ តាមមាត្រា ៣៣ថ្មី ចំណុចទី២(ជ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧-ផ្អែកតាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសន្និដ្ឋានថា សុំឱ្យសភាព្រហ្មទណ្ឌសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទនោះ សភាព្រហ្មទណ្ឌពុំលើកយកមកពិចារណាឡើយ។ សភាព្រហ្មទណ្ឌគប្បីលើកយកចំណុចទណ្ឌកម្មលើជនជាប់ចោទរូបនេះមកពិចារណាអំពីកំរិតទណ្ឌកម្មឱ្យសមល្មមតាមកំរិតល្មើស និងសមទណ្ឌទៅនឹងជនជាប់ចោទផ្សេងទៀត។

៨-សាលក្រមព្រហ្មទណ្ឌលេខ ៩៥"ង"ចុះថ្ងៃទី ០៨-៨-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ សម្រេចមានលក្ខណៈត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី២ ស្តីពីទណ្ឌកម្មលើជនជាប់ចោទឈ្មោះ ហ៊ឹម វណ្ណា គប្បីបន្ធូបន្ថយតាមច្បាប់។

ហេតុដូច្នេះ

**<u>វិនិច្ឆ័យសេចក្តី</u>**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤-៩-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ទុកជាត្រឹមត្រូវតាមច្បាប់។



Scanned with CamScanner

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៥"ង"ចុះថ្ងៃទី ០៨-៨-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ លើកលែងតែចំណុចទី១ ត្រូវបដិសេធចោល និងចំណុចទី២ ស្តីពីទណ្ឌកម្មលើឈ្មោះ [redacted] វណ្ណា ត្រូវតែប្រែមកត្រឹមចំនួន ០៥ឆ្នាំ(ប្រាំឆ្នាំ) វិញ ពីបទ: ជួញដូរគ្រឿងញៀនខុសច្បាប់,ប្រព្រឹត្តនៅភូមិនិមិត្ត២ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ,កាលពីថ្ងៃទី ០៨-០៥-២០១០។ តាមមាត្រា ៣៣ថ្មី ចំណុចទី២-ជ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ចំណុចផ្សេងពីនេះ រក្សាទុកជាបានការដដែល។

៤-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៥-សាលដីកានេះប្រកាសជាសាធារណ: នៅថ្ងៃទី ២៤-១២-២០១៣ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងជនជាប់ចោទ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ ត្រូវចាត់ចែងជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

សាលាឧទ្ធរណ៍ថ្ងៃទី ១៤ ខែ ០៣ ឆ្នាំ ២០១៤

| បានឃើញ | |
|---|---|
| **ប្រធានសាលាឧទ្ធរណ៍** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |

March 2014



Scanned with CamScanner